**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរកសិកម្មខេត្តស្វាយរៀង**

**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម** ស្វាយរៀង,ថ្ងៃទី. ..១៦....ខែ....សីហា.....ឆ្នាំ ២០១៦

**លេខ.៣៤ ក អ ស**

**សូមគោរពចូលមក**

**លោកប្រធានមន្ទីរកសិកម្មខេត្តស្វាយរៀង**

**តាមរយៈ លោកប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

**កម្មវត្ថុ: របាយការណ៍លទ្ធផលទស្សនៈកិច្ចសិក្សាដកស្រង់ ផ្លាស់ប្តូរ បទពិសោធន៍ស្តីពីការគ្រប់គ្រង និងដំណើរការមុខរបរ របស់សហគមន៍កសិកម្ម ខេត្តកំពង់ចាម**

**នាថ្ងៃទី ១០ដល់ ១២ ខែ សីហា ឆ្នាំ២០១៦**

## ១.សេចក្តីផ្តើម

យោងតាមសំណើរបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម លេខ ២៨៥ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១៦ស្តីពីសំណើ សុំចាត់មន្ត្រី និងតំណាងសហគមន៍កសិកម្ម ដើម្បីចូលរួមទស្សនៈកិច្ចដកស្រង់ ផ្លាស់ប្តូរបទពិសោធន៍សហគមន៍កសិកម្មនៅខេត្តកំពង់ចាម ។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនិងការិយាល័យអភិវឌ្ឍន៍សហគមន៍នៃមន្ទីកសិកម្មខេត្តស្វាយរៀងបានជ្រើសរើសនិងរៀបចំដំណើរទស្សនៈកិច្ចសិក្សានេះលើសហគមន៍កសិកម្មចំនួន០៨ក្នុងខេត្តកំពង់ចាមរួមមានៈសហគមន៍កសិកម្មសំបូរមានជ័យសហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យសហគមន៍កសិកម្មត្រើងសាមគ្គីមានជ័យនិងសហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង ។

**គោលបំណងនៃទស្សនៈសិក្សាៈ**

- សិក្សាស្វែងយល់ពីដំណើរការរៀបចំបង្កើតផែនការមុខរបររបស់សហគមន៍កសិកម្ម
- សិក្សាស្វែងយល់ពីខ្សែសង្វាក់ផលិតកម្មនិងទីផ្សាររបស់សហគមន៍កសិកម្ម
- សិក្សាស្វែងយល់ពីបច្ចេកទេសផលិតស្រូវនិងការជម្រុញការងារកសិកម្មការចូលរួមធ្វើអាជីវកម្មជាមួយសហគមន៍កសិកម្ម
- យុទ្ធសាស្រ្តក្នុងការគៀងគរកជំនួយនិងការគាំទ្រពីបណ្តាដៃគូសហការនិងវិស័យឯកជននានា

**សមាសភាពអ្នកចូលរួម៖**

- មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ០២ រូប
- មន្ត្រីការិផ្សព្វផ្សាយកសិកម្មនិង ការិ.អភិសហគមន៍កសិកម្មខេត្តកំពង់ចាម០២រូប
- មន្ត្រីការិយាល័យអភិវឌ្ឍន៍កសិកម្មនៃមន្ទីរកសិកម្មខេត្តស្វាយរៀង ០៣ រូប
- មន្ត្រីការិយាល័យកសិកម្មស្រុកគោលដៅទាំងបី)០៣ រូប
- តំណាងសហគមន៍សហគមន៍កសិកម្មរស្មីបឹងអណ្តែង ០១ រូប
- តំណាងសហគមន៍កសិកម្មសាមគ្គីឃុំសំឡី ០១ រូប
- តំណាងសហគមន៍កសិកម្មស្វាយជ្រំ ០១ រូប
- តំណាងសហគមន៍កសិកម្ម ទងផ្លូករីកចម្រើន ០១ រូប
- តំណាងសហគមន៍កសិកម្ម កសិករត្នោតថ្មី ០១ រូប
- តំណាងសហគមន៍កសិកម្ម ចម្រើនផលស្វាយរំពារ ០១ រូប
- តំណាងសហគមន៍កសិកម្ម ម្រាមផ្តល់ផល ០១ រូប
- តំណាងសហគមន៍កសិកម្ម ផលិតពូជស្រូវដូនទយ ០១រូប

សរុបអ្នកចូលរួមមានចំនួន ១៨ នាក់ ស្រី ០៤ នាក់ ។

## ២ .បទបង្ហាញអំពីស្ថានភាពទូទៅ និងស្ថានភាពសហគមន៍កសិកម្មរបស់ខេត្តកំពង់ចាម

### ២.១ ស្ថានភាពភូមិសាស្ត្រនិងការងារផលិតកម្មកសិកម្ម

ខេត្តកំពង់ចាមមានទីតាំងស្ថិតនៅវាលទំនាបកណ្តាលនៃទន្លេមេគង្គ មានផ្ទៃដី៤,៥៤៨.០៩ គ.ម$^២$ប្រជាជនចំនួន ១ ៦៨០ ៩៩៤ នាក់ មាន ០៩ ស្រុក និងក្រុង ០១ មានព្រំប្រទល់ជាប់ ៖

ខាងជើងជាប់ ខេត្តកំពង់ធំ ក្រចេះ
ខាងត្បូងជាប់ខេត្តកណ្តាល ព្រៃវែង
ខាងកើតជាប់ ខេត្តត្បូងឃ្មុំ
ខាងលិចជាប់ខេត្តកំពង់ឆ្នាំង

ផ្ទៃដីចដាំដុះសរុបចំនួន ៖ ២៥៤ ៧៤ ហ.ត

ផ្ទៃដីដាំស្រូវ ៖ ១១៨ ៧៨៨ ហ.ត

ស្រូវវស្សា ៖ ៨៧ ១៤៤៦ ហ.ត

ស្រូវប្រាំង ៖ ៣១ ៦៤២ ហ.ត

ដំណាំរួមផ្សំ ៖ ៧៤ ០២២ ហ.ត

ដំណាំរយៈឧស្សាហកម្ម៖ ៣៦ ៦៨៩ ហ.ត

ដំណាំសក្តានុពលរួមមាន: ស្រូវ ម្រេច កៅស៊ូ ស្វាយចន្ទី ....។

### ២.២ ស្ថានភាពសហគមន៍កសិកម្ម

ចាប់ពីឆ្នាំ

២០១៣មកដល់បច្ចុប្បន្ន(កាត់ដៃនរដ្ឋបាលខេត្តត្បូងឃ្មុំ)មានសហគមន៍កសិកម្មចំនួន ១៨

សមាជិកសរុប: ១៤ ៦៦ នាក់ ,ស្រី ៦៦៨ នាក់

ចំនួនហ៊ុនសរុប: ១០ ៨៣៩
ប្រាក់ភាគហ៊ុនសរុប: ៥៥៣ ០០០ ០០០ រៀល
ជំនួយផ្សេងៗ ១៨៩ ០០០ ០០០ រៀល
សរុបទុន: ២ ០០០ ០០០ ០០០ រៀល

**មុខរបរសហគមន៍កសិកម្មសំខាន់ៗ៖**

ឥណទានកសិកម្មខ្នាតតូច
ផលិតកម្មគ្រាប់ពូជ
ឥណទានស្រូវ
ផលិតកូនមាន់
ផ្គត់ផ្គង់ធាតុចូលកសិកម្ម ចំណីសត្វ
ការច្នៃកសិផល

**បញ្ហាជួបប្រទះ**

ការគ្រប់គ្រងដឹកនាំសហគមន៍
កង្វះដើមទុន
ការចូលរួមរបស់សមាជិក
តម្លៃ និងទីផ្សារកសិផល

## ៣ បទបង្ហាញស្តីពីការគ្រប់គ្រងសហគមន៍

### ៣.១ សហគមន៍កសិកម្មស្ទឹងត្រង់មានជ័យ

#### ក. ប្រវត្តិសហគមន៍

សហគមន៍ស្ទឹងត្រង់មានជ័យបានផ្តួចផ្តើមបង្កើតឡើងដោយក្នុងឆ្នាំ ២០១០ ដោយមានការគាំទ្រ មន្ទីរកសិកម្មខេត្តកំពង់ចាម។ សហគមន៍នេះបានទទួលជំនួយ ពីគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប (TSSD)មានសមាជិកសរុបចំនួន ៧៤ នាក់ មានហ៊ុនសរុប ចំនួន ១,២២៩ ហ៊ុន តម្លៃមួយ ហ៊ុន គឺ ៥០,០០០ រៀល បច្ចុប្បន្នសហគមន៍នេះមានរបរសំខាន់ៗ៖

- ឥណទានកសិកម្មខ្នាតតូច
- ឥណទានចំណីសត្វ
- មុខរបរផ្គត់ផ្គង់ (ថ្នាំ និងចំណីសត្វ)
- មុខរបរព្យាបាលសត្វ
- កែច្នៃចំណីសត្វ
- លក់កូនជ្រូក

#### ខ. ស្ថានភាពនិងការដឹកនាំសហគមន៍

សហគមន៍អភិវឌ្ឍន៍កសិកម្មត្រើងមានជ័យ មានថ្នាក់ដឹកនាំ ចំនួន ០៨ រូបស្រ្តី ០២ ការគ្រប់គ្រងនិងដំណើរការ ការងារទូទៅក្នុងសហគមន៍ ត្រូវបានបែងចែកភារកិច្ចនិងការទទួលខុសត្រូវរួមគ្នា និង រៀងៗខ្លួនតាមតួនាទីដែលបានកំណត់ និងមានកាជួយសម្របសម្រួល ពីមន្ទីរកសិកម្ម និងគម្រោង (TSSD)ប្រចាំខេត្តកំពង់ចាម។

**លក្ខណៈពិសេសដែលនាំសហគមន៍នេះបានទទួលជោគជ័យ**

- គោរពតាមគោលការណ៍ គ្រិះ ច្បាប់ និង បទបញ្ញត្តិនានារបស់សហគមន៍
- ចូលរួមរបស់សមាជិក (តម្លាភាព)
- សេវាកម្ម(តម្លៃ គុណភាពផលិតផល)

- សេវាកម្មប្រឹក្សាបច្ចេកទេស (ជ្រើសរើសពូជ ចំណី ថែទាំ )
- ភាពស្មោះត្រង់ និង អធ្យាស្រ័យ ។

## ៣.២ សហគមន៍កសិកម្មត្រើងសាមគ្គីមានជ័យ

### ក. ប្រវត្តិសហគមន៍

សហគមន៍ត្រើងសាមគ្គីមានជ័យបានផ្តួចផ្តើមបង្កើតឡើងដោយក្នុងឆ្នាំ ២០០៦ ដោយមានការគាំទ្រ អង្គការការីតាសកម្ពុជា ប៉ុន្តែបានផ្អាកដំណើរការ មិនមានសកម្មភាពនោះទេ ហើយនៅចុងឆ្នាំ២០១៣

សហគមន៍កសិកម្មនេះមានសកម្មភាពដំណើរការឡើងវិញដោយមានការគាំទ្រពី មន្ទីរកសិកម្មខេត្តកំពង់ចាមនិង

អង្គការការីតាសកម្ពុជាវិញបច្ចុប្បន្ននេះសហគមន៍មានសមាជិកសរុបចំនួន ៩០នាក់ ស្រី ២៧ មាន ហ៊ុនសរុប ចំនួន ៣៣៧ ហ៊ុន មានទុនសរុប ១០១ ៩៩២ ០០០ រៀល  មានរបរសំខាន់ៗៈ

ឥណទានកសិកម្មខ្នាតតូច - ដេប៉ូលក់គ្រឿងទេស

មុខរបរផ្គត់ផ្គង់ (ផ្គត់ផ្គង់មេផ្សិត និង វត្ថុធាតុដើមផលិត) - សិប្បកម្មដោយដៃ(តុ.កៅ.អីឬស្សី)

- ទីផ្សារកសិកផល (បន្លែ សាច់) - ផលិតទឹកម្ទេស តៅហ៊ូ
- ផលិតកូនមាន់លក់ - លក់ គោ (យកចំណេញ)
- សេវាកម្មផ្គត់ផ្គង់ទឹក(អណ្តូង ការីតាស) - សេវាកម្មបង្រៀនបច្ចេកទេសកែច្នៃ

### ខ. ស្ថានភាពនិងការដឹកនាំសហគមន៍

សហគមន៍អភិវឌ្ឍន៍កសិកម្មត្រើងសាមគ្គីមានជ័យ មានថ្នាក់ដឹកនាំ ចំនួន ០៨ រូប ស្រ្តី ០៤ បុគ្គលិកកិច្ចសន្យា ០២ រូប ។ ការគ្រប់គ្រងនិងដំណើរការ ការងារទូទៅក្នុងសហគមន៍ត្រូវបានបែងចែកភារកិច្ចនិងការទទួលខុសត្រូវរួមគ្នា និងរៀងៗខ្លួនតាមតួនាទីដែលបានកំណត់ និងមានការជួយសម្របសម្រួល ពីមន្ទីរកសិកម្ម និង អង្គការការីតាសកម្ពុជា ។

### គ. ផែនការ និង យុទ្ធសាស្ត្រទីផ្សារសហគមន៍

-

សហគមន៍កសិកម្មត្រើងសាមគ្គីមានជ័យបានអនុវត្តផលិតកម្មតាមកិច្ចសន្យាលើដំណាំផ្សិតចំបើង

- សហគមន៍បានគ្រោងការ បង្កើតផ្សារចល័ត (Mart TukTuk)លក់ដូរ ផលិតផលកសិកម្ម (បន្លែ សាច់គ្រឿងទេស ទឹកម្ទេស តៅហ៊ូ )
- បញ្ជូនផលិតសហគមន៍ទៅទីផ្សារអតិថិជន តាមកិច្ចសន្យា ធានាគុណភាព ផលិត និង បរិមាណ

-ពង្រឹងសមត្ថភាព សមាជិក និង ធានាគុណភាពផលិតផល ការវេចខ្ចប់ផលិតផល

- ជម្រុញការដាំដុះដំណាំបន្លែអាកាស ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ ការបណ្តុះផ្សិត ។

-

លក្ខខណ្ឌអង្គការនានាដែលចូលមកជួយកសិករក្នុងមូលដ្ឋានត្រូវស្នើសុំការសម្របសម្រួលពីសហគមន៍កសិកម្មត្រើងសាមគ្គីមានជ័យ ។

**លក្ខណៈពិសេសដែលនាំសហគមន៍នេះបានទទួលជោគជ័យ**

- គោរពតាមគោលការណ៍ ត្រិះ ច្បាប់ និង បទបញ្ញត្តិនានារបស់សហគមន៍
- ចូលរួមរបស់សមាជិក (តម្លាភាព)
- សេវាកម្ម(តម្លៃ គុណភាពផលិតផល)
- សេវាកម្មប្រឹក្សាបច្ចេកទេស (ប្រើប្រាស់ពូជ ជី ថ្នាំ ដល់អតិថិជន)
- ភាពស្មោះត្រង់ និង អធ្យាស្រ័យ
- មានយុទ្ធសាស្ត្រទីផ្សារ និងគ្រប់គ្រងដឹកនាំ ច្បាស់លាស់។

## ៣.៣ សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង

### ក. ប្រវត្តិសហគមន៍

សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើងបានផ្តួចផ្តើមបង្កើតឡើងដោយក្នុងឆ្នាំ ២០០៧ ដោយមានការគាំទ្រ អង្គការសេដា និង មន្ទីរកសិកម្មខេត្តកំពង់ចាម សហគមន៍នេះមានសមាជិកសរុបចំនួន ៣៥០ នាក់ មានហ៊ុនសរុប ចំនួន ២,៨៧៩ ហ៊ុន ។ សហគមន៍នេះមានរបរសំខាន់ៗៈ

- ឥណទានកសិកម្មខ្នាតតូច -ទីផ្សារអង្ករ (ពូជ១០មុខ)
- មុខរបរផ្គត់ផ្គង់ (ថ្នាំ ជី ចំណីសត្វ) - សេវាកម្មកិនស្រូវ(រោងម៉ាស៊ីនកិនស្រូវ)

### ខ. ស្ថានភាពនិងការដឹកនាំសហគមន៍

សហគមន៍អភិវឌ្ឍន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង មានថ្នាក់ដឹកនាំ ចំនួន ០៨ រូប ស្ត្រី ០២ ការគ្រប់គ្រងនិងដំណើរការ ការងារទូទៅក្នុងសហគមន៍ ត្រូវបានបែងចែកភារកិច្ចនិងការទទួលខុសត្រូវរួមគ្នា និងរៀងៗខ្លួនតាមតួនាទីដែលបានកំណត់ និងមានការជួយសម្របសម្រួល ពីមន្ទីរកសិកម្ម ខេត្តកំពង់ចាម។

### គ. ផែនការ និង យុទ្ធសាស្ត្រទីផ្សារសហគមន៍

- សហគមន៍កសិកម្មដំណើការលក់អង្ករទៅកាន់ទីផ្សារក្នុងតំបន់ និង ភ្នំពេញ
- សហគមន៍បានគ្រោងការ

បង្កើតផ្សារសហគមន៍កសិកម្មនៅទីតាំងសហគមន៍ផ្ទាល់ក្នុងការលក់ដូរ ផលិតផលកសិកម្ម (បន្លែ អង្ករ គ្រាប់ពូជ កន្ទក់ អង្កាម ជី ថ្នាំកសិកម្ម )

- ផ្សព្វផ្សាយ និង បញ្ជូនផលិតសហគមន៍ទៅទីផ្សារផ្ទាល់តាមរយៈ

បញ្ញើរលក់ផ្តល់សេវាកម្មដល់ដេប៉ូ ហាងលក់ទំនិញ

- ពង្រឹងសមត្ថភាព សមាជិក និង ធានាគុណភាពផលិតផល ការវេចខ្ចប់ផលិតផល

## ៣.៤ សហគមន៍កសិកម្មសំបូរមានជ័យ

### ក. ប្រវត្តិសហគមន៍

សហគមន៍សំបូរមានជ័យបានផ្តួចផ្តើមបង្កើតឡើងដោយក្នុងឆ្នាំ ២០១០ ដោយមានការគាំទ្រ មន្ទីរកសិកម្មខេត្តកំពង់ចាម សហគមន៍នេះ មានសមាជិកសរុបចំនួន ១៥៦ នាក់ មានហ៊ុនសរុប ចំនួន ៣,៣៣៦ ហ៊ុន បច្ចុប្បន្នសហគមន៍មានទុនសរុប ៦៦២ ១៧១ ១០០ រៀល មានរបរសំខាន់ៗ៖

- ឥណទានកសិកម្មខ្នាតតូច
- ដេប៉ូលក់គ្រឿងទេស
- មុខរបរផ្គត់ផ្គង់ (ថ្នាំ ជី និង គ្រាប់ពូជ)
- ឥណទានជីកសិកម្ម

### ខ. ស្ថានភាពនិងការដឹកនាំសហគមន៍

សហគមន៍អភិវឌ្ឍន៍កសិកម្មសំបូរមានជ័យ មានថ្នាក់ដឹកនាំ ចំនួន ០៨ រូប ស្ត្រី ០២ ការគ្រប់គ្រងនិងដំណើរការ ការងារទូទៅក្នុងសហគមន៍ ត្រូវបានបែងចែកភារកិច្ចនិង ការទទួលខុសត្រូវរួមគ្នា និង
រៀងៗខ្លួនតាមតួនាទីដែលបានកំណត់ និងមានការជួយសម្របសម្រួល ពីមន្ទីរកសិកម្ម និងគម្រោង (TSSD)ប្រចាំខេត្តកំពង់ចាម។

### គ. ផែនការ និង យុទ្ធសាស្ត្រទីផ្សារសហគមន៍

- សហគមន៍កសិកម្មសំបូរមានជ័យបានអនុវត្តការកម្ចីប្រាក់ដោយឥតការប្រាក់ រយៈពេល ១៥ ថ្ងៃ ដល់សមាជិក ក្នុងករណីសមាជិកជួបប្រទះបញ្ហាបន្ទាន់
- សហគមន៍បានគ្រោងការ
បង្កើតផ្សារសហគមន៍កសិកម្មនៅទីតាំងសហគមន៍ផ្ទាល់ក្នុងការលក់ដូរ ផលិតផលកសិកម្ម (បន្លែ ត្រី សាច់ អង្ករ គ្រាប់ពូជ)
- ផ្សព្វផ្សាយ និង បញ្ជូនផលិតសហគមន៍ទៅទីផ្សារផ្ទាល់តាមរយៈ
បញ្ញើរលក់ផ្តល់សេវាកម្មដល់ដេប៉ូ ហាងលក់ទំនិញ
- ពង្រឹងសមត្ថភាព សមាជិក និង ធានាគុណភាពផលិតផល ការវេចខ្ចប់ផលិតផល
- ការទទួលស្គាល់គុណភាព គ្រាប់ពូជ មន្ទីរកសិកម្ម និង គម្រោង (TSSD) និង
ការបណ្តុះបណ្តាលពីវិទ្យាស្ថាន ស្រាវជ្រាវនិង អភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)
-ផែនការផលិតកម្មដំណាំល្ហុង ផ្គត់ផ្គង់ទីផ្សារ ភ្នំពេញ និង ហាងលក់ម្ហូរ និង សហគ្រាសកែច្នៃ
- គ្រោងការ ផលិតកម្មតាមកិច្ចសន្យា គ្រាប់ពូជជាមួយ ក្រុមហ៊ុនឯកជន និង សហគមន៍ដៃគូ

ក្រោយពេលទស្សនៈកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីការគ្រប់គ្រង និង ដំណើរការផលិតកម្មរបស់សហគមន៍កសិកម្មកំពង់ចាមបានប្រព្រឹត្ត
ទៅដោយជោគជ័យហើយសិក្ខាកាមដែលចូលរួមទាំងអស់បានចែករំលែកបទពិសោធន៍ពីគ្នាទៅវិ

ញទៅមកនិងទទួលបានបទពិសោធន៍ថ្មីៗបន្ថែមទៀតពីទស្សនៈកិច្ចសិក្សានេះរួមមានទ្រឹស្តីនិងការអនុវត្តជាក់ស្តែងទៅលើការងារគ្រប់គ្រងសហគមន៍
ការបង្កើតមុខរបរសហគមន៍វិធីសាស្ត្រពង្រីកសមាជិក
សម្រាប់យកទៅអនុវត្តនៅតាមបណ្តាសហគមន៍រៀងៗខ្លួន។ទស្សនៈកិច្ចសិក្សាដកស្រង់បទពិសោធន៍នេះពិតជាមានផលប្រយោជន៍និងសារៈសំខាន់ណាស់សម្រាប់បង្កើនចំណេះដឹងនិងបទពិសោធន៍ដល់ថ្នាក់ដឹកនាំសហគមន៍កសិកម្មដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍
វិស័យការងារសហគមន៍កសិកម្មប្រកបដោយនិរន្តភាពនិងចែករំលែកបទពិសោធន៍ចំណេះដឹងល្អៗដែលទទួលបានទាំងអស់នេះដល់សមាជិក
ក្នុងការលើកស្ទួយជីវភាពរស់នៅតាមរយៈការងារសហគមន៍កសិកម្ម  ការចូលរួមសាមគ្គីធ្វើជំនួញការដាំដុះដំណាំរួមផ្សំគ្រប់ប្រភេទយល់ដឹងពីបច្ចេកទេសនៃការទុកដាក់កែច្នៃនិងដឹកជញ្ជូនផលិតផល ការទំនាក់ទំនងទីផ្សារ តួនាទីភារកិច្ចរបស់សហភាពសហគមន៍ ។

(ជូនភ្ជាប់រូបថតសកម្មភាព)

អាស្រ័យដូចបានជម្រាបជូនក្នុងរបាយការណ៍ខាងលើនេះសូមលោកប្រធានមន្ទីរមេត្តាជ្រាបជារបាយការណ៍ ។

អ្នកធ្វើរបាយការណ៍

នួន ទិត្យភារាម

## សកម្មភាពៈមតិសំណេះសំណាលស្វាគមន៍របស់លោកអនុប្រធានមន្ទីរ កសិកម្មកំពង់ចាមតំណាងប្រធានមន្ទីរ



## សកម្មភាពៈបទបង្ហាញពីការគ្រប់គ្រងដំណើរការមុខរបរផលិតចំណីសត្វ សហគមន៍កសិកម្មស្ទឹងត្រង់មានជ័យ





## បទបង្ហាញ:ដំណើរការមុខរបរ និងការផលិតគ្រាប់ពូជសហគមន៍កសិកម្ម សំបូរមានជ័យ



## សកម្មភាព:បទបង្ហាញ ពីដំណើរការប្រមូលទិញ និង ផ្គត់ផ្គង់អង្ករទៅទីផ្សារសហគមន៍អភិវឌ្ឍន៍ស្រុកយើង





# បទបង្ហាញៈដំណើរការគ្រប់គ្រងមុខរបរ និង
# យុទ្ធសាស្ត្រទីផ្សារសហគមន៍កសិកម្មត្រើងសាមគ្គីមានជ័យ






## ផលិតផលរបស់សហគមន៍កសិកម្មត្រើងសាមគ្គីមានជ័យ




